# កន្លែងដាក់កាតរូបភាពសមាជិកគ្រួសារ



# ប្រមូលកាតគ្រួសារ

សកម្មភាព ៖

សិក្សាសង្គម ៖ បំណិនទំនាក់ទំនង៖ អត្តសញ្ញាណរបស់ខ្លួន

បុរេគណិត ៖ បរិមាណ និងចំនួន៖ ស្គាល់និងយល់លេខតាងនិងការគណនាលេខសាមញ្ញៗ៖

គោលបំណង ៖

សិក្សាសង្គម ៖ ប្រាប់បានពីនាមត្រកូល នាមខ្លួន ចំនួនសមាជិកក្នុងគ្រួសារ និងជាកូនទីប៉ុន្មាន

បុរេគណិត ៖ ប្រាប់បានពីចំនួន លេខ និងយល់ពីន័យពីលេខ១ ដល់៣០តាមលំដាប់លំដោយ ឬលើសពីនេះ

រយៈពេល ៖ ៣០ នាទី

ឧបករណ៍ ៖ គ្រាប់ឡុកឡាក់ សម្ភារសម្គាល់ខ្លួនកុមារ ក្រដាសក្តារល្បែង

កម្រិតសិក្សា ៖ មធ្យម និង ខ្ពស់

ការរៀបចំ ៖ រៀបចំកាត់កាតគ្រួសារដែលមានលោកតា លោកយាយ ម្តាយ ឪពុក កូនប្រុស កូនស្រី និងសម្ភារទាំងអស់ដែលប្រើសម្រាប់ការលេងល្បែងនេះ។

សេក្តីណែនាំ ៖

១.ចែកកុមារទៅជាក្រុមៗដែលមានពី៣ ទៅ ៤នាក់ក្នុងមួយក្រុម។

២.ចែកសម្ភារសម្រាប់លេងមួយក្រុម១ឈុត ដែលមានក្រដាសក្តារល្បែង សម្ភារសម្គាល់ខ្លួន គ្រាប់ឡុកឡាក់ កាតតូចៗដែលបានកាត់រួចរាល់។

៣.នៅចំកណ្តាលក្រដាសក្តារល្បែង ទុកដាក់កាតសមាជិកគ្រួសារ។

៤.តាមក្រុមនីមួយៗត្រូវស្វែងរកអ្នកដែលត្រូវចាប់ផ្តើមមុន ដោយប៉ាវ ឬវិធីអ្វីក៏បាន។

៥.កុមារទី១ ចាប់ផ្តើមបោះគ្រាប់ឡុកឡាក់ និងចាប់ផ្តើមដើរទៅតាមចំនួនលេខដែលបានទទួលបាននោះ។

៦.មាន៤ករណីសម្រាប់លេងល្បែងនេះ មានដូចជា៖

-នៅពេលដែលដើរចំរូបភាពសមាជិកគ្រួសារមួយណា អាចយករូបភាពនោះដែលនៅចំកណ្តាលមួយសន្លឹកបាន (បញ្ជាក់៖ មានសិទ្ធិយកបានតែ១សន្លឹកតែប៉ុណ្ណោះ)

-នៅពេលដែលដើរចំប្រអប់ដែលមានសញ្ញាបេះដូង អ្នកនោះមានសិទ្ធិយកកាតរូបភាពមួយបាន (យករូបភាពសមាជិកគ្រួសារមួយដែលមិនជាន់គ្នាជាមួយកាត់សមាជិកគ្រួសារដែលបានរើសយកពីមុន)

-នៅពេលដែលអ្នកដើរចំប្រអប់ដែលមានសញ្ញាការ៉េ អ្នកនោះត្រូវដកកាតរូបភាពដាក់ចូលក្នុងចំកណ្តាលវិញមួយសន្លឹក (កាតរូបភាពសមាជិកមួយណាក៏បានដែរ)

-នៅពេលដែលអ្នើដើរចំប្រអប់ដែលមានសញ្ញាខ្វែងអ្នកនឹងគ្មានសិទ្ធិយកកាតទេ

៧.កុមារម្នាក់ៗត្រូវស្វែងរកកាតសមាជិកគ្រួសារឱ្យបានប្រាំមួយ ដែលរួមមាន៖ លោកតា លោកយាយ លោកពុក ម្តាយ កូនប្រុស កូនាស្រី។

នៅពេលដែលកុមារម្នាក់ណាបានប្រាំមួយកាតគ្រប់សមាជិកគ្រួសារ គឺជាអ្នកឈ្នះទី១ ទី២...។

៨.កុមារមិនអាចយកការដែលមដូចគ្នាបាននោះទេ ប្រសិនជាដើរចំប្រអប់ដែលមានកាតនោះហើយ ត្រូវដាក់វានៅចំកន្លែងដដែលវិញ និងប្តូរវេនទៅកុមារបន្ទាប់តែម្តង។ ត្រូវដើរពីឆ្វេងទៅស្តាំតែមួយទិសដៅគត់។

៩.លេងបែបនេះរហូតដល់កុមារដែលទទួលបានរូបភាពសមាជិកគ្រួសារបានគ្រប់មុននិងអស់គ្រប់គ្នាគឺជាការស្រេច។

| | | | | | |
|---|---|---|---|---|---|
|  លោកយាយ |  លោកតា |  ឪពុក |  ម្តាយ |  កូនស្រី |  កូនប្រុស |
|  លោកយាយ |  លោកតា |  ឪពុក |  ម្តាយ |  កូនស្រី |  កូនប្រុស |
|  លោកយាយ |  លោកតា |  ឪពុក |  ម្តាយ |  កូនស្រី |  កូនប្រុស |
|  លោកយាយ |  លោកតា |  ឪពុក |  ម្តាយ |  កូនស្រី |  កូនប្រុស |






















៥
៦ ៣ ១ ៤
២


៥
៦ ៣ ១ ៤
២


៥
៦ ៣ ១ ៤
២


៥
៦ ៣ ១ ៤
២


៥
៦ ៣ ១ ៤
២


៥
៦ ៣ ១ ៤
២


៥
៦ ៣ ១ ៤
២


៥
៦ ៣ ១ ៤
២


៥
៦ ៣ ១ ៤
២